ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារ
# ច្បាប់ អនុក្រឹត្យ និងប្រកាសនានា
# ស្តីពី
# ការត្រួតពិនិត្យផលិតផលថ្នាំជក់
# ក្នុងប្រទេសកម្ពុជា

បោះពុម្ពដោយមជ្ឈការជាតិ ២០១៦

# មាតិកា


១. ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់.................................................ទំព័រទី២

២. អនុក្រឹត្យស្តីពី ការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ

និងរូបភាពលើកញ្ចប់ផលិតផលថ្នាំជក់................................................ទំព័រទី១៦

៣. ប្រកាសស្តីពី នីតិវិធីបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ

និងរូបភាពលើកញ្ចប់ផលិត ផលថ្នាំជក់................................................ទំព័រទី២២

៤. ប្រកាសស្តីពី វិធានការចំពោះការដាក់តាំងបង្ហាញកញ្ចប់ផលិតផលថ្នាំជក់...........ទំព័រទី២៧

៥. អនុក្រឹត្យស្តីពី វិធានការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ

ឬ កន្លែងសាធារណៈ .............................................................................ទំព័រទី៣១

៦. ប្រកាសស្តីពី ស្លាកបម្រាមនៃការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់. .ទំព័រទី៣៦

# ព្រះរាជក្រម

នស/រកម/០៥១៥/០០៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាលើកទី៤ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៥ នាសម័យប្រជុំជាវិសាមញ្ញ នីតិកាលទី៣ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

# ច្បាប់

# ស្ដីពី

# ការត្រួតពិនិត្យ

# ផលិតផលថ្នាំជក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

ច្បាប់នេះមានគោលបំណងការពារសុខភាពសាធារណៈ និងកាត់បន្ថយផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច សង្គម និងបរិស្ថាន ដែលបណ្តាលមកពីផលិតផលថ្នាំជក់ ។

**មាត្រា ២.-**

ច្បាប់នេះមានគោលដៅដូចតទៅ ៖

- កំណត់វិធានការក្នុងការគ្រប់គ្រង និងត្រួតពិនិត្យផលិតផលថ្នាំជក់ ។
- លើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់សាធារណជន អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់
- សហការជាមួយបណ្តាក្រសួង ស្ថាប័នជាតិ អន្តរជាតិ និងអង្គការដៃគូនានា ដើម្បីជំរុញការអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ៣.-**

ច្បាប់នេះមានវិសាលភាពអនុវត្តលើគ្រប់សកម្មភាពពាក់ព័ន្ធនឹងផលិតផលថ្នាំជក់គ្រប់ប្រភេទ ដែលផលិតនៅក្នុងស្រុក ឬនាំចូលពីបរទេស ហើយចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ៤.-**

វាក្យសព្ទបច្ចេកទេសសំខាន់ៗដែលប្រើក្នុងច្បាប់នេះមាននិយមន័យដូចតទៅ ៖

- **ផលិតផលថ្នាំជក់** សំដៅដល់ផលិតផលគ្រប់ប្រភេទផ្សំឡើងពីសន្លឹកថ្នាំជក់ សរសៃថ្នាំជក់ ឬសារធាតុនៃថ្នាំជក់ដែលផលិតដោយឧស្សាហករថ្នាំជក់ ឬដោយមធ្យោបាយផ្សេងៗទៀតដែលប្រើប្រាស់សម្រាប់ជក់ដោយផ្ទាល់ ឬដោយទម្រង់ផ្សេងៗទៀត រួមមាន ជញ្ជក់ ទំពា បុក ឬហិត ។
- **ឧស្សាហករថ្នាំជក់** សំដៅដល់ផលិតករថ្នាំជក់ អ្នកលក់ដុំ និងអ្នកនាំចូលផលិតផលថ្នាំជក់ ។
- **ការឧបត្ថម្ភធីដោយឧស្សាហកម្មថ្នាំជក់** សំដៅដល់រាល់ទម្រង់នៃវិភាគទានចំពោះព្រឹត្តិការណ៍ សកម្មភាព ឬបុគ្គលណាមួយ ដោយមានគោលបំណងមានអានុភាពលើ ឬអាចមានអានុភាពលើការផ្សព្វផ្សាយផលិតផលថ្នាំជក់ ឬការប្រើប្រាស់ផលិតផលថ្នាំជក់ដោយផ្ទាល់ ឬដោយប្រយោល ។


ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- កញ្ចប់ផលិតផលថ្នាំជក់ សំដៅដល់ប្រអប់ ក្រដាស គ្រឿងរុំពីក្រៅ ឬវត្ថុវេចខ្ចប់ផលិតផលថ្នាំជក់ ដោយមិនរាប់បញ្ចូលបាវ ឬវត្ថុសម្រាប់ផ្ទុកផលិតផលថ្នាំជក់របស់កសិករ ។
- សារព្រមានសុខភាព សំដៅដល់សារជាភាសាខ្មែរ និងជារូបភាពដែលបោះពុម្ពលើកញ្ចប់ផលិតផលថ្នាំជក់ បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ និងព័ត៌មាន ពាក់ព័ន្ធផ្សេងទៀត ។
- គ្រឹះស្ថានសិក្សា សំដៅដល់មជ្ឈមណ្ឌលអប់រំ សិក្សា បណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត ។
- គ្រឹះស្ថានសុខាភិបាល សំដៅដល់ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យ គ្លីនិកសុខភាពទាំងរដ្ឋ ទាំងឯកជន ឱសថស្ថាន មន្ទីរពិសោធន៍សុខាភិបាលជាដើម ។
- បរិយាកាសគ្មានផ្សែងថ្នាំជក់ សំដៅដល់ខ្យល់ដែលគ្មានផ្សែងថ្នាំជក់ ១០០% រួមទាំងខ្យល់ដែលមិនអាចមើលឃើញផ្សែងថ្នាំជក់ ធុំក្លិន ឬវាស់ស្ទង់បាន ។
- គ្រឹះស្ថានសាសនា សំដៅដល់ព្រះវិហារ ធម្មសភា សាលាបុណ្យ កុដិ បណ្ណាល័យសាលា ពុទ្ធិកសិក្សា អាស្រម មណ្ឌលវិបស្សនា វិហារស៊ូរ៉ាវជាដើម ដែលទីកន្លែងទាំងនោះ ប្រើប្រាស់ក្នុងគោលបំណងគោរពបូជាសាសនាផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា ។

## ជំពូកទី ២
## សមត្ថកិច្ចត្រួតពិនិត្យថ្នាំជក់

**មាត្រា ៥.-**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការត្រួតពិនិត្យរាល់សកម្មភាពពាក់ព័ន្ធនឹងផលិតផលថ្នាំជក់គ្រប់ប្រភេទដែលបញ្ញត្តក្នុងច្បាប់នេះ ។

**មាត្រា ៦.-**

ក្រសួងសុខាភិបាលជាស្ថាប័នបង្គោលជាតិសម្រាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងបណ្តារដ្ឋភាគីនៃអនុសញ្ញាស្តីពីការត្រួតពិនិត្យថ្នាំជក់ របស់អង្គការសុខភាពពិភពលោក និងលេខាធិការដ្ឋាននៃអនុសញ្ញា ព្រមទាំងអង្គការជាតិ និងអង្គការអន្តរជាតិពាក់ព័ន្ធ ។

ROYAUME DU CAMBODGE ... CONTRE DU PALAIS

**មាត្រា ៧.-**

រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីអប់រំ និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់ ។

គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវដឹកនាំដោយរដ្ឋមន្ត្រីក្រសួងសុខាភិបាល និងមានការចូលរួមពីក្រសួងស្ថាប័នពាក់ព័ន្ធ ។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣
## ការបង្ហាញព័ត៌មានសមាសធាតុក្នុងផលិតផលថ្នាំជក់ និងការដាក់បង្ហាញសារព្រមានសុខភាព

**មាត្រា ៨.-**

ផលិតករក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ និងលក់ ក្នុងករណីមានតម្រូវការចាំបាច់ត្រូវផ្ដល់ជូនក្រសួងសុខាភិបាលនូវព័ត៌មានលម្អិតអំពីសមាសធាតុដែលមានក្នុងផលិតផលថ្នាំជក់ និងផ្សែងថ្នាំជក់ ។

ព័ត៌មានលម្អិតអំពីសមាសធាតុដែលមានក្នុងផលិតផលថ្នាំជក់ និងផ្សែងថ្នាំជក់ ត្រូវកំណត់ដោយប្រកាស របស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៩.-**

ការប្រើប្រាស់ពាក្យដែលទាក់ទាញ និងធ្វើឲ្យយល់ច្រឡំ ជាអាទិ៍ ក្លិនឈ្ងុយឆ្ងាញ់ រសជាតិស្រាល រសជាតិស្រាលស្រទន់ រសជាតិវីតាមីន កាហ្វេអ៊ីនក្នុងផលិតផលថ្នាំជក់ ត្រូវហាមឃាត់ ។

**មាត្រា ១០.-**

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទ សម្រាប់ធ្វើការចែកចាយលក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ អំពីគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ ។

សារព្រមានសុខភាពជារូបភាព ត្រូវមានទំហំ ៥០ (ហាសិប) ភាគរយយ៉ាងតិច ។ ការបោះពុម្ពសារព្រមានសុខភាពជាអក្សរ និងរូបភាព ត្រូវកំណត់ដោយអនុក្រឹត្យ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៤
# វិធានការចំពោះការផ្សាយពាណិជ្ជកម្ម ការផ្សព្វផ្សាយលក់ និងការឧបត្ថម្ភកម្មវិធីដោយឧស្សាហករថ្នាំជក់

## មាត្រា ១១.-

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់តាមប្រព័ន្ធផ្សព្វផ្សាយជារូបភាព ឬជាអក្សរ ឬជាសំឡេង តាមរយៈវិទ្យុ ទូរទស្សន៍ សារព័ត៌មាន ទស្សនាវដ្ដី ស៊ីឌី វីស៊ីឌី ឌីវីឌី សេវាប្រៃសណីយ៍ សេវាទូរគមនាគមន៍ និងតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗទៀត ត្រូវហាមឃាត់ ។

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជាផ្ទាំងរូបភាព ផ្ទាំងប៉ាណូ ផ្ទាំងបដា ផ្ទាំងគំនូរ ឬបណ្ណផ្សព្វផ្សាយ ផលិតផលថ្នាំជក់ផ្សេងៗទៀតជាសាធារណៈ និងការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ជារូបភាពចលត៌ នៅលើជញ្ជាំងរថយន្ត ឬលើយានជំនិះ និងមធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ត្រូវហាមឃាត់ ។

ការផ្សាយពាណិជ្ជកម្មផលិតផលថ្នាំជក់ដល់សាធារណជននៅតាមទីកន្លែងសាធារណៈណាមួយ ដូចជាក្នុងកម្មវិធីប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីផ្សេងៗទៀត និងការលើកកម្ពស់ការផ្សព្វផ្សាយផលិតផល ថ្នាំជក់ដល់អតិថិជនដោយផ្ទាល់ ឬដោយប្រយោល ដោយភ្នាក់ងារក្រុមហ៊ុនផលិតថ្នាំជក់ ត្រូវហាមឃាត់ ។

## មាត្រា ១២.-

ចំពោះការដាក់តាំងបង្ហាញកញ្ចប់ផលិតផលថ្នាំជក់ធម្មតា អាចធ្វើទៅបានតែនៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារីផ្ទាល់តែប៉ុណ្ណោះ ។

ទំហំ និងចំនួននៃកញ្ចប់ផលិតផលថ្នាំជក់ដែលដាក់តាំងបង្ហាញ ឬបិទនៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារី ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

## មាត្រា ១៣.-

ការឧបត្ថម្ភកម្មវិធីក្នុងការប្រគំតន្ត្រី ឬកម្មវិធីកីឡា ឬកម្មវិធីជាសាធារណៈផ្សេងៗទៀត ជាផលិតផលថ្នាំជក់ ឬជាសម្ភារៈដែលបង្ហាញពីឈ្មោះផលិតផលថ្នាំជក់ត្រូវហាមឃាត់ ។

# ជំពូកទី៥
# ការចែកចាយ ការលក់ និងទីកន្លែងលក់ផលិតផលថ្នាំជក់

## មាត្រា ១៤.-

ការគ្រប់គ្រង និងត្រួតពិនិត្យលើការលក់រាយ ការចែកចាយ និងការលក់ដុំផលិតផលថ្នាំជក់គ្រប់ប្រភេទ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា ១៥.-**

ការលក់ និងការចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ និងស្ត្រីដែលមានគភ៌ ត្រូវហាមឃាត់ កាលបើគភ៌នោះ ត្រូវបានគេឃើញជាក់ស្តែង ឬកាលបើអ្នកលក់បានដឹង ។

ការលក់រាយមួយកញ្ចប់ក្រោម ២០ ដើម ត្រូវហាមឃាត់ ។

**មាត្រា ១៦.-**

រាល់ការនាំយកមកជាមួយខ្លួននូវបារី ឬផលិតផលថ្នាំជក់ដើម្បីប្រើប្រាស់ផ្ទាល់ខ្លួន ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជា លើសពី ២០០ (ពីររយ) ដើម ឬស៊ីហ្គាលើស ៥០ (ហាសិប) ដើម ឬថ្នាំជក់ទម្ងន់លើស ២៥០ (ពីររយហាសិប) ក្រាម ត្រូវហាមឃាត់ ។

ជនដែលមានអាយុតិចជាង ១៨ (ដប់ប្រាំបី) ឆ្នាំ មិនអនុញ្ញាតឲ្យនាំយកមកជាមួយខ្លួននូវបារី ឬផលិតផលថ្នាំជក់ចូលមកក្នុងព្រះរាជាណាចក្រកម្ពុជាឡើយ ។

**មាត្រា ១៧.-**

ការលក់ និងចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទ នៅក្នុងបរិវេណនៃគ្រឹះស្ថានសិក្សា គ្រឹះស្ថាន សុខាភិបាល សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ត្រូវហាមឃាត់ ។

ការលក់ផលិតផលថ្នាំជក់គ្រប់ប្រភេទ តាមមធ្យោបាយមិនផ្ទាល់ តាមរយៈម៉ាស៊ីនលក់ដោយស្វ័យប្រវត្តិ ការបញ្ជាទិញតាមប្រៃសណីយ៍ និងការបញ្ជាទិញតាមសេវាទូរគមនាគមន៍ផ្សេងៗ ត្រូវហាមឃាត់ ។

## ជំពូកទី ៦
## វិធានការការពារបរិយាកាស
## គ្មានផ្សែងផលិតផលថ្នាំជក់

**មាត្រា ១៨.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ និងចាត់វិធានការការពារប្រជាពលរដ្ឋ ពីការប្រឈមនឹងការស្រូបផ្សែងផលិតផលថ្នាំជក់ ដើម្បីធានាសិទ្ធិអ្នកមិនប្រើប្រាស់ផលិតផលថ្នាំជក់ ឲ្យទទួលបាននូវបរិយាកាសដែលគ្មានផ្សែងផលិតផលថ្នាំជក់ ដើម្បីបង្ការនូវជំងឺផ្សេងៗដែលបណ្តាលមកពីការស្រូបផ្សែងផលិតផលថ្នាំជក់ និងផលប៉ះពាល់ដល់សុខភាពដែលបង្កឡើងដោយផ្សែងផលិតផលថ្នាំជក់ ។

**មាត្រា ១៩.-**

វិធានការហាមការជក់ និងការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅកន្លែងធ្វើការ និងកន្លែងសាធារណៈ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ការវាយតម្លៃអំពីហានិភ័យ ការតាមដាន ការត្រួតពិនិត្យ និងការសិក្សាស្រាវជ្រាវ

**មាត្រា ២០.-**

ក្រសួងសុខាភិបាលត្រូវសហការជាមួយគ្រប់ស្ថាប័នពាក់ព័ន្ធ ដើម្បីធានាឲ្យមានការវាយតម្លៃសមស្របអំពីហានិភ័យនៃសកម្មភាពទាក់ទងនឹងផលិតផលថ្នាំជក់ សម្រាប់ធ្វើការតាមដាន ត្រួតពិនិត្យ និងសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច បរិស្ថាន និងសង្គម ។

**មាត្រា ២១.-**

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការសិក្សាស្រាវជ្រាវអំពីផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ច បរិស្ថាន និងសង្គម ដោយផ្តោតលើការងារដូចខាងក្រោម ៖

- ការប្រើប្រាស់ផលិតផលថ្នាំជក់
- បរិមាណផលិតផលថ្នាំជក់ដែលនាំចេញ នាំចូល តម្លៃ និងការប្រើប្រាស់ថ្នាំជក់ វត្ថុធាតុដើម គ្រឿងម៉ាស៊ីន ប្រាក់ចំណូល ការដាំដំណាំថ្នាំជក់ និងព័ត៌មានផ្សេងៗទៀត
- ប្រសិទ្ធភាពនៃការអនុវត្តគោលនយោបាយត្រួតពិនិត្យថ្នាំជក់ ។

**មាត្រា ២២.-**

ក្រសួងសុខាភិបាល និងស្ថាប័នពាក់ព័ន្ធ ត្រូវរៀបចំឲ្យមានក្រុមជំនាញវិទ្យាសាស្ត្រ និងមន្ទីរពិសោធន៍ ដើម្បីធ្វើតេស្តផលិតផលថ្នាំជក់ ជាពិសេស ស្តង់ដានៃសមាសធាតុ និងផលប៉ះពាល់ដែលកើតចេញពីការប្រើប្រាស់ផលិតផលថ្នាំជក់ ក្នុងករណីចាំបាច់ ត្រូវសហការជាមួយក្រុមជំនាញវិទ្យា-សាស្ត្រ និងមន្ទីរពិសោធន៍ក្នុងតំបន់ និងអន្តរជាតិ ។

## ជំពូកទី ៨
## ការផ្តល់ព័ត៌មាន ការលើកកម្ពស់ ការយល់ដឹង និងការចូលរួមរបស់សាធារណជន

**មាត្រា ២៣.-**

ក្រសួងសុខាភិបាល គណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ និងស្ថាប័នពាក់ព័ន្ធត្រូវលើកកម្ពស់ការយល់ដឹង ធ្វើការអប់រំ និងផ្តល់ព័ត៌មានគ្រប់គ្រាន់ដល់សាធារណជន អំពីផលប៉ះពាល់លើសុខភាព សេដ្ឋកិច្ច និងបរិស្ថានដែលបណ្តាលមកពីការប្រើប្រាស់ផលិតផលថ្នាំជក់ ។

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច អាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល និងផ្នែកឯកជនដែលគ្មានទំនាក់ទំនងជាមួយឧស្សាហកម្មថ្នាំជក់ដើម្បីជំរុញកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ២៤.-**

ក្រសួងសុខាភិបាល និងគណៈកម្មាធិការត្រួតពិនិត្យផលិតផលថ្នាំជក់ ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីលើកទឹកចិត្តដល់ការចូលរួមរបស់សាធារណជន ក្នុងកម្មវិធីលើកកម្ពស់ការយល់ដឹងជាសាធារណៈនៅទូទាំងប្រទេស តាមរយៈការអប់រំ និងយុទ្ធនាការផ្សព្វផ្សាយទូលំទូលាយ និងជួយអ្នកប្រើប្រាស់ផលិតផលថ្នាំជក់ឲ្យឈប់ប្រើប្រាស់ផលិតផលថ្នាំជក់ ។

**មាត្រា ២៥.-**

អ្នកផ្តល់សេវាសុខាភិបាលគ្រប់ប្រភេទ ទាំងសាធារណៈ ទាំងឯកជន ត្រូវចូលរួម និងផ្តល់ការអប់រំ ផ្សព្វផ្សាយអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់ ដល់សាធារណជន និងអតិថិជនរបស់ខ្លួន ។

**មាត្រា ២៦.-**

ក្រសួងទទួលបន្ទុកវិស័យអប់រំ ត្រូវបញ្ចូលកម្មវិធីលើកកម្ពស់ការយល់ដឹងអំពីផលវិបាកនៃការប្រើប្រាស់ផលិតផលថ្នាំជក់ ទៅក្នុងកម្មវិធីសិក្សាចំណេះទូទៅ ទាំងសាធារណៈ និងឯកជន ។

**មាត្រា ២៧.-**

រាជរដ្ឋាភិបាលត្រូវយកចិត្តទុកដាក់ចំពោះកសិករ ដែលស្ម័គ្រចិត្តប្តូរការដាំដំណាំថ្នាំជក់ ទៅដំណាំផ្សេងវិញ ។

## ជំពូកទី ៦
## គោលនយោបាយពន្ធលើផលិតផលថ្នាំជក់

**មាត្រា ២៨.-**

រាជរដ្ឋាភិបាលត្រូវមានគោលនយោបាយដំឡើងពន្ធលើផលិតផលថ្នាំជក់គ្រប់ប្រភេទ ទៅតាមស្ថានភាពសមស្រប ។

**មាត្រា ២៩.-**

រាជរដ្ឋាភិបាលត្រូវរៀបចំឲ្យមានមូលនិធិត្រួតពិនិត្យផលិតផលថ្នាំជក់ ដើម្បីកាត់បន្ថយការប្រើ-ប្រាស់ និងផលប៉ះពាល់នៃការប្រើប្រាស់ថ្នាំជក់ អប់រំសុខភាព លះបង់ទម្លាប់ប្រើប្រាស់ផលិតផលថ្នាំ-

ជក់ ស្រាវជ្រាវ និងវាយតម្លៃកម្មវិធីត្រួតពិនិត្យផលិតផលថ្នាំជក់ និងសម្រាប់ជួយកសិករឲ្យលះបង់ការដាំដំណាំថ្នាំជក់ និងក្នុងគោលបំណងផ្សេងៗទៀត ដើម្បីបម្រើសុខភាពសាធារណៈ ។

មូលនិធិត្រួតពិនិត្យផលិតផលថ្នាំជក់នេះ ត្រូវបង្កើតដោយអនុក្រឹត្យ ។

## ជំពូកទី ១០
## អធិការកិច្ចផលិតផលថ្នាំជក់

### មាត្រា ៣០.–

ក្រសួងសុខាភិបាលត្រូវចាត់តាំងមន្ត្រីជំនាញរបស់ក្រសួង ជាមន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ដើម្បីតាមដាន ត្រួតពិនិត្យ និងជំរុញការអនុវត្តច្បាប់នេះ ។

### មាត្រា ៣១.–

ក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការទាក់ទងនឹងការធ្វើអធិការកិច្ចដែលមានចែងក្នុងច្បាប់នេះ មន្ត្រីអធិការកិច្ច ផលិផលថ្នាំជក់មានសិទ្ធិធ្វើការត្រួតពិនិត្យ និងចាត់វិធានការដូចខាងក្រោម ៖

- ធ្វើការត្រួតពិនិត្យជាប្រចាំទៅលើការប្រើប្រាស់ ការលក់ និងការផ្សព្វផ្សាយពាណិជ្ជកម្ម និងការបោះពុម្ពសារព្រមានសុខភាពលើផលិតផលថ្នាំជក់របស់ឧស្សាហករថ្នាំជក់
- ស្នើសុំត្រួតពិនិត្យ និងធ្វើតេស្តលើសមាសធាតុផលិតផលថ្នាំជក់ ដែលមាននៅក្នុងផលិតផលថ្នាំជក់ និងនៅក្នុងផ្សែងថ្នាំជក់
- ចាត់វិធានការហាមឃាត់ជាបណ្តោះអាសន្នចំពោះការចែកចាយ ឬការចរាចរ លើទីផ្សារនូវប្រភេទផលិតផលថ្នាំជក់ទាំងឡាយណាដែលបានស្រាវជ្រាវឃើញនូវសមាសធាតុដែលបង្កហានិភ័យខ្ពស់ក្នុងផលិតផលថ្នាំជក់ ឬបង្កគ្រោះថ្នាក់ធ្ងន់ធ្ងរចំពោះសុខភាពមនុស្ស និងបរិស្ថាន
- ត្រួតពិនិត្យ និងពិន័យអន្តរការណ៍ចំពោះការមិនអនុវត្តបទដ្ឋានគតិយុត្តផ្សេងទៀតដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់
- ចាប់យកវត្ថុតាង និងបិទស្លាកបោះត្រាលើវត្ថុតាងនៃបទល្មើស
- បំពេញការកិច្ចផ្សេងទៀតតាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

នីតិវិធីនៃការធ្វើអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

### មាត្រា ៣២.–

មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ទទួលនីតិសម្បទាឲ្យពិនិត្យបទល្មើសដែលមានចែងក្នុងច្បាប់នេះ ស្របតាមបទប្បញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

[illegible]បទ និងនីតិវិធីនៃការផ្តល់នីតិសម្បទាចំពោះមន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣៣.-**

រាល់ប្រតិបត្តិការពិនិត្យបទល្មើសរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ មានសិទ្ធិស្នើសុំជំនួយពីអាជ្ញាធរដែនដីគ្រប់ថ្នាក់ និងអង្គភាពប្រដាប់អាវុធ ឬអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធផ្សេងទៀត ដើម្បីចូលរួមបង្ក្រាបបទល្មើសដែលមានចែងក្នុងច្បាប់នេះ ។

**មាត្រា ៣៤.-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ត្រូវស្លៀកពាក់ឯកសណ្ឋាន និងមានបណ្ណសម្គាល់ខ្លួន ព្រមទាំងមានលិខិតអនុញ្ញាតឲ្យបំពេញបេសកកម្ម ។

ឯកសណ្ឋាន និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល ។

**មាត្រា ៣៥.-**

បុគ្គលដែលមិនសុខចិត្តចំពោះវិធានការណាមួយរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់ អាចធ្វើបណ្ដឹងតវ៉ាក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ នៃថ្ងៃធ្វើការ ទៅរដ្ឋមន្ត្រីក្រសួងសុខាភិបាល គិតចាប់ពីថ្ងៃទទួលបានសេចក្ដីសម្រេច ឬថ្ងៃដកហូត ។

រដ្ឋមន្ត្រីក្រសួងសុខាភិបាលត្រូវសម្រេចបណ្ដឹងក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការយ៉ាងយូរ គិតពីថ្ងៃទទួលពាក្យបណ្ដឹង ។

ក្នុងករណីដែលបុគ្គលណាមិនសុខចិត្តចំពោះសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល បុគ្គលនោះមានសិទ្ធិធ្វើបណ្ដឹងទៅតុលាការតាមនីតិវិធី ។

**មាត្រា ៣៦.-**

នៅពេលប្រតិបត្តិការអនុវត្តច្បាប់នេះ ក្នុងករណីវត្ថុតាងនៃបទល្មើសជាផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់ មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់មានសិទ្ធិស្នើសុំដីកាសម្រេចរបស់ព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោលដោយអនុលោមតាមនីតិវិធីជាធរមាន ។

ការចំណាយលើការបំផ្លាញចោលវត្ថុតាងដូចមានចែងខាងលើ គឺជាបន្ទុករបស់ម្ចាស់វត្ថុតាងនៃបទល្មើស ។

**មាត្រា ៣៧.-**

ប្រាក់ពិន័យអន្តរការណ៍ត្រូវបង់ចូលថវិការដ្ឋ ។ រាជរដ្ឋាភិបាលអាចសម្រេចផ្ដល់រង្វាន់លើកទឹកចិត្តដល់មន្ត្រី ដែលបានចូលរួមក្នុងករណីបង្ក្រាបបទល្មើសជាក់លាក់ណាមួយដែលចែងក្នុងច្បាប់នេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១១
# ទោសប្បញ្ញត្តិ

### មាត្រា ៣៨.-

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែ ទៅ ៦ (ប្រាំមួយ) ខែ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីមិនរាងចាល ត្រូវផ្តន្ទាទោសទ្វេដង ។

### មាត្រា ៣៩.-

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៩ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។ ក្នុងករណី ធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើស ដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

### មាត្រា ៤០.-

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១០ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤ ០០០ ០០០ (បួនលាន) រៀល ទៅ ២០ ០០០ ០០០ (ម្ភៃលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើស ដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

### មាត្រា ៤១.-

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១១ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើស ដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

## មាត្រា ៤២.-

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១២ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៤ ០០០ ០០០ (បួនលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

## មាត្រា ៤៣.-

ផលិតករថ្នាំជក់ក្នុងស្រុក និងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ១៣ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀល ទៅ ៤០ ០០០ ០០០ (សែសិបលាន) រៀល ។

ក្នុងករណីធ្លាប់ទទួលរងការផ្តន្ទាទោសពិន័យជាស្ថាពររួចហើយ ហើយបានប្រព្រឹត្តបទល្មើសដដែលនេះក្នុងអំឡុងពេល ២ (ពីរ) ឆ្នាំ ត្រូវផ្តន្ទាទោសពិន័យទ្វេដង ។

## មាត្រា ៤៤.-

អំពើលក់ ឬចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទដល់ជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ឬស្ត្រីដែលមានគភ៌ កាលបើគភ៌នោះត្រូវបានគេឃើញជាក់ស្តែង ឬកាលដែលខ្លួនបានដឹងត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ថ្ងៃ ទៅ ១ (មួយ) ខែ និងពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ។

## មាត្រា ៤៥.-

រាល់បរិមាណ ចំនួនបារី ឬផលិតផលថ្នាំជក់ដែលត្រូវបានបញ្ញត្តហាមឃាត់ដោយមាត្រា ១៦ នៃច្បាប់នេះ ត្រូវរឹបអូសដោយមន្ត្រីមានសមត្ថកិច្ច ។

## មាត្រា ៤៦.-

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០០ ០០០ (មួយសែន) រៀល ទៅ ១ ០០០ ០០០ (មួយលាន) រៀល ចំពោះអំពើលក់ ឬចែកចាយផលិតផលថ្នាំជក់គ្រប់ប្រភេទ នៅក្នុងបរិវេណនៃគ្រឹះស្ថានសិក្សា គ្រឹះស្ថានសុខាភិបាល សួនកុមារ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានប្រវត្តិសាស្ត្រ កន្លែងពិព័រណ៍ ស្ថានីយ ប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ។

ត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០ ០០០ (ពីរសែន) រៀល ទៅ ២ ០០០ ០០០ (ពីរលាន) រៀល ចំពោះអំពើលក់ផលិតផលថ្នាំជក់គ្រប់ប្រភេទតាមមធ្យោបាយមិនផ្ទាល់ តាមរយៈម៉ាស៊ីនលក់ដោយស្វ័យប្រវត្តិ តាមការបញ្ជាទិញតាមប្រៃសណីយ៍ និងតាមការបញ្ជាទិញតាមសេវាទូរគមនាគមន៍ផ្សេងៗ ។

**មាត្រា ៤៧.-**

នីតិបុគ្គលអាចត្រូវប្រកាសថាត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា ៣៨ ដល់មាត្រា ៤៣ និងកថាខណ្ឌទី ២ មាត្រា ៤៦ នៃច្បាប់នេះ ។

នីតិបុគ្គលត្រូវពិន័យជាប្រាក់ទ្វេដង ព្រមទាំងទោសបន្ថែមណាមួយ ឬច្រើនដូចតទៅនេះ ៖

១- ការរំលាយតាមបែបបទកំណត់ដោយមាត្រា ១៧០ (ការរំលាយ និងការជម្រះបញ្ជីនៃនីតិបុគ្គល) នៃក្រមព្រហ្មទណ្ឌ ។

២- ការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យតាមដានរបស់តុលាការ តាមបែបបទកំណត់ដោយមាត្រា ១៧១ (ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមដានរបស់តុលាការ) នៃក្រម-ព្រហ្មទណ្ឌ ។

៣- ការហាមឃាត់ចំពោះការធ្វើសកម្មភាពមួយ ឬច្រើន តាមបែបបទកំណត់ដោយមាត្រា ១៧២ (ការហាមឃាត់ចំពោះការធ្វើសកម្មភាព) នៃក្រមព្រហ្មទណ្ឌ ។

៤- ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោស តាមបែបបទកំណត់ដោយមាត្រា ១៨០ (ការបិទផ្សាយសេចក្តីសម្រេច) នៃក្រមព្រហ្មទណ្ឌ ។

៥- ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងសារព័ត៌មានសរសេរឬការផ្សាយតាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ តាមបែបបទកំណត់ដោយមាត្រា ១៨១ (ការផ្សាយសេចក្តីសម្រេចតាមមធ្យោបាយទូរគមនាគមន៍សោតទស្សន៍ ជាអាទិ៍) នៃក្រមព្រហ្ម-ទណ្ឌ ។

## ជំពូកទី ១២
## អន្តរប្បញ្ញត្តិ

**មាត្រា ៤៨.-**

បទដ្ឋានគតិយុត្តដែលពាក់ព័ន្ធនឹងការត្រួតពិនិត្យផលិតផលថ្នាំជក់ ដែលនៅជាធរមាន នៅមានសុពលភាពរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ១៣
## អវសានប្បញ្ញត្តិ

**មាត្រា ៤៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

ការល: ១៥០៥.៤៥៥

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**
**ហត្ថលេខា**
**ម៉ម ប៊ុនហេង**

លេខ [illegible] ណ
**សំណៅដែល[illegible]ជាការចែកផ្សាយ**
រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០១៥
**អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល**

**សយ សុខា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៨៩ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងការពារសុខភាពសាធារណៈនិងកាត់បន្ថយផលប៉ះពាល់ដល់សុខភាព សេដ្ឋកិច្ចសង្គម និងបរិស្ថានដែលបណ្តាលមកពីផលិតផលថ្នាំជក់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅជាអាទិ៍៖

- កំណត់វិធានការក្នុងការគ្រប់គ្រងការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់
- អប់រំផ្សព្វផ្សាយអំពីផលវិបាកនិងគ្រោះថ្នាក់នៃការប្រើប្រាស់ផលិតផលថ្នាំជក់ ដើម្បីកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់
- បង្ការកុមារនិងយុវជនពីការចាប់ផ្តើមប្រើប្រាស់ផលិតផលថ្នាំជក់។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពលើការអនុវត្តចំពោះការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់គ្រប់ប្រភេទដែលត្រូវបានចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- កញ្ចប់ផលិតផលថ្នាំជក់ សំដៅដល់ប្រអប់ ក្រដាស គ្រឿងរុំពីក្រៅឬវត្ថុវេចខ្ចប់ផលិតផលថ្នាំជក់ ដោយមិនរាប់បញ្ចូលបាវឬវត្ថុសម្រាប់ផ្ទុកផលិតផលថ្នាំជក់របស់កសិករ។
- សារព្រមានសុខភាព សំដៅដល់សារជាភាសាខ្មែរនិងជារូបភាពដែលត្រូវបោះពុម្ពលើកញ្ចប់ផលិតផលថ្នាំជក់ បង្ហាញពីគ្រោះថ្នាក់នៃការប្រើប្រាស់ថ្នាំជក់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀត។

# ជំពូកទី២
# សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ការត្រួតពិនិត្យនិងការអនុវត្តអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងសុខាភិបាល។

# ជំពូកទី៣
# វិធានការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់

**មាត្រា៦ .-**

ផលិតផលថ្នាំជក់ដែលផលិតក្នុងស្រុកឬនាំចូលសម្រាប់ចែកចាយ លក់ និងប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់។

**មាត្រា៧ .-**

ទំហំនិងទីតាំងនៃរូបភាពសារព្រមានសុខភាពដែលត្រូវបោះពុម្ពលើកញ្ចប់ផលិតផលថ្នាំជក់ត្រូវឆ្លើយតបនឹងលក្ខណៈពិសេសដូចខាងក្រោម៖

- សារព្រមានសុខភាពលើកញ្ចប់ផលិតផលថ្នាំជក់ជារូបភាពត្រូវមានទំហំ៥០% និងសារជាភាសាខ្មែរត្រូវមានទំហំ៥% លើផ្ទៃសំខាន់ខាងមុខនិងផ្ទៃសំខាន់ខាងក្រោយ ឬនៅលើផ្ទៃសំខាន់ទាំងអស់ប្រសិនកញ្ចប់មានផ្ទៃលើសពីពីរ។
- សារព្រមានសុខភាពត្រូវបោះពុម្ពលើផ្ទៃសំខាន់ផ្នែកខាងលើនៃកញ្ចប់ផលិតផលថ្នាំជក់ទាំងសងខាង។
- សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពត្រូវមានភាពងាយមើល ច្បាស់លាស់ មិនហើរពណ៌ មិនរលុប មិនត្រួតគ្នា។
- សារព្រមានសុខភាពជាភាសាខ្មែរត្រូវបោះពុម្ពជាអក្សរដិតពណ៌សលើផ្ទៃពណ៌ខ្មៅនៅផ្នែកខាងលើជាប់សារព្រមានសុខភាពជារូបភាព។

**មាត្រា៨ .-**

សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពមិនត្រូវបិទបាំងដោយការវេចខ្ចប់ កំណត់សម្គាល់ ឬស្លាកផ្សេងៗដែលមានគោលបំណងរារាំងដល់សារព្រមានសុខភាពដូចមានចែងក្នុងអនុក្រឹត្យនេះ លើកលែងតែការបិទតែមប្រើអាករ។

**មាត្រា៩ .-**

គំរូសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ដូចមានចែងក្នុងមាត្រា៦និងមាត្រា៧នៃអនុក្រឹត្យនេះ និងរបៀបនៃការផ្លាស់ប្តូរជារៀងទាត់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

## ជំពូកទី៤
## ទោសប្បញ្ញត្តិ

**មាត្រា១០ .-**

ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់មន្ត្រីអធិការកិច្ចផលិតផលថ្នាំជក់។

**មាត្រា១១ .-**

នីតិវិធីនៃការពិន័យអន្តរការណ៍លើអំពើល្មើសដូចមានចែងក្នុងអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២ .-**

ផលិតករថ្នាំជក់ក្នុងស្រុកនិងអ្នកនាំចូលផលិតផលថ្នាំជក់គ្រប់ប្រភេទសម្រាប់ធ្វើការចែកចាយ លក់ និងប្រើប្រាស់ដែលមិនអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា៥នៃអនុក្រឹត្យនេះត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន៤ ០០០ ០០០(បួនលាន)រៀល។

ក្នុងករណីដែលទទួលពិន័យអន្តរការណ៍ម្តងរួចមកហើយ នៅតែប្រព្រឹត្តល្មើសទៀត ត្រូវទទួលពិន័យទ្វេដង។

**មាត្រា១៣ .-**

អ្នកចែកចាយនិងអ្នកលក់ដុំផលិតផលថ្នាំជក់គ្រប់ប្រភេទដែលចែកចាយនិងលក់ផលិតផលថ្នាំជក់គ្មានសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ឬបិទបាំងដោយការវេចខ្ចប់ កំណត់សម្គាល់ ឬស្លាកផ្សេងៗដែលរារាំងដល់គោលបំណងនៃសារព្រមានសុខភាព ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន២ ០០០ ០០០

(ពីរលាន)រៀល។ ក្នុងករណីទទួលពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែប្រព្រឹត្តល្មើសទៀត ត្រូវទទួលពិន័យទ្វេដង។

**មាត្រា១៤ .-**

អ្នកលក់រាយផលិតផលថ្នាំជក់គ្រប់ប្រភេទដែលចែកចាយនិងលក់ផលិតផលថ្នាំជក់គ្មានសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាព ឬបិទបាំងដោយការវេចខ្ចប់ កំណត់សម្គាល់ ឬស្លាកផ្សេងៗដែលរារាំងដល់គោលបំណងនៃសារព្រមានសុខភាព ត្រូវទទួលពិន័យអន្តរការណ៍ជាប្រាក់ចំនួន១០ ០០០(មួយម៉ឺន)រៀល។ ក្នុងករណីទទួលពិន័យអន្តរការណ៍ម្តងរួចហើយ នៅតែប្រព្រឹត្តល្មើសទៀត ត្រូវទទួលពិន័យទ្វេដង។

**មាត្រា១៥ .-**

មន្ត្រីមានសមត្ថកិច្ចណាមួយដែលរំលោភបំពានមុខងារ ដូចមានចែងក្នុងមាត្រា៩នៃអនុក្រឹត្យនេះ ត្រូវទទួលទណ្ឌកម្មខាងវិន័យរដ្ឋបាលនិងទោសដែលមានក្នុងច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី៥
## អន្តរប្បញ្ញត្តិ

**មាត្រា១៦ .-**

ផលិតករក្នុងស្រុកនិងអ្នកនាំចូលសម្រាប់ធ្វើការចែកចាយនិងលក់ផលិតផលថ្នាំជក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តតាមអនុក្រឹត្យនេះ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមានបានរយៈពេល៩(ប្រាំបួន)ខែ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា១៧ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសាផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៨ ._**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ ៧ ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ០១៦៣៣ សស.ប្រ.ក

# ប្រកាស
## ស្តីពី
## នីតិវិធីបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាព លើកញ្ចប់ផលិតផលថ្នាំជក់

## រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ ៦៧អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ១៤៩អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់គំរូ និងនីតិវិធីនៃការផ្លាស់ប្តូរសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ដែលផលិតក្នុងស្រុក ឬនាំចូលសម្រាប់ចែកចាយ និងលក់នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់នេះមាន២ (ពីរ) គំរូ សម្រាប់អនុវត្តក្នុងមួយឆ្នាំៗដូចមានចែងក្នុងឧបសម្ព័ន្ធ។

ក្នុងករណីមិនទាន់មានសេចក្តីណែនាំថ្មីអំពីគំរូសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាព ត្រូវបន្តអនុវត្តសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ ដែលមានក្នុងឧបសម្ព័ន្ធនេះរហូតមានសេចក្តីណែនាំថ្មី ។

**ប្រការ៣.-**

សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់ត្រូវផ្លាស់ប្តូររៀងរាល់មួយឆ្នាំម្តង កំណត់ដោយសេចក្តីណែនាំរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**ប្រការ៤.-**

សារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពទាំង២ (ពីរ) គំរូដូចមានចែងក្នុងឧបសម្ព័ន្ធត្រូវបោះពុម្ពនៅលើកញ្ចប់ផលិតផលថ្នាំជក់ដោយមានបរិមាណស្មើគ្នាក្នុងពេលតែមួយ។

**ប្រការ៥.-**

ការប្រព្រឹត្តល្មើសនឹងប្រកាសនេះ ត្រូវផ្តន្ទាទោសតាមបញ្ញត្តិដែលមានចែងក្នុងច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ និងអនុក្រឹត្យស្តីពីការបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរនិងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាលដែលពាក់ព័ន្ធ ត្រូវអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០១៦

**កន្លែងទទួល**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោហ៊ុនសែន
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ម៉ម ប៊ុនហេង**

# ឧបសម្ព័ន្ធទី១

## នៃប្រកាសលេខ : ០១៣ស / ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦

## ស្តីពីនីតិវិធីបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់

**គំរូប្លង់សារ និងរូបភាពព្រមានសុខភាពលើកញ្ចប់បារី**

**មាត្រដ្ឋាន : ១ / ១**



# ឧបសម្ព័ន្ធទី២

## នៃប្រកាសលេខ : ០៦៣ស / ប្រ.ក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០១៦

## ស្តីពីនីតិវិធីបោះពុម្ពសារព្រមានសុខភាពជាភាសាខ្មែរ និងជារូបភាពលើកញ្ចប់ផលិតផលថ្នាំជក់

**<u>គំរូប្លង់សារ និងរូបភាពព្រមានសុខភាពលើកញ្ចប់បារី</u>**

**មាត្រដ្ឋាន : ១ / ១**



ក្រសួងសុខាភិបាល

លេខ: ១១២៧ អបស

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ប្រកាស

# ស្តីពី

# វិធានការចំពោះការដាក់តាំងបង្ហាញកញ្ចប់ផលិតផលថ្នាំជក់

* * * *

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ សន/រកម/០៥១៥/០០៨ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

# សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់វិធានការអំពីការដាក់តាំងបង្ហាញនិងកំណត់ចំនួនកញ្ចប់ផលិតផលថ្នាំជក់ ការផ្សាយពាណិជ្ជកម្មនិងការផ្សព្វផ្សាយលក់ផលិតផលថ្នាំជក់ ការឧបត្ថម្ភកម្មវិធីពីផលិតផលថ្នាំជក់ នៅនឹងកន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់បារី នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

កន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់ផលិតផលថ្នាំជក់ត្រូវបានអនុញ្ញាតឱ្យដាក់សម្ភារៈសម្រាប់តាំងលក់កញ្ចប់បារីធម្មតាបានតែមួយគត់។

សម្ភារៈសម្រាប់តាំងលក់កញ្ចប់បារីត្រូវមានក្រឡាផ្ទៃទំហំមិនលើសពី ២០០០ (ពីរពាន់) សង់ទីម៉ែត្រការ៉េ ដែលមានបណ្តោយប្រវែង៥០(ហាសិប)សង់ទីម៉ែត្រ និងទទឹងប្រវែង៤០(សែសិប) សង់ទីម៉ែត្រ។

ផ្ទៃដាក់តាំងនិងផ្ទៃផ្សេងទៀតនៃសម្ភារៈសម្រាប់តាំងលក់កញ្ចប់បារី ត្រូវមានពណ៌ខ្មៅតហើយលាត។

**ប្រការ៣.-**

កន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់ផលិតផលថ្នាំជក់ត្រូវបានអនុញ្ញាតឱ្យដាក់តាំងលក់ផលិតផលថ្នាំជក់ក្នុងមួយម៉ាកតែមួយកញ្ចប់ប៉ុណ្ណោះ។

**ប្រការ៤.-**

កន្លែងលក់ ឬតូបលក់ ឬក្នុងហាងលក់ផលិតផលថ្នាំជក់ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយលក់ផលិតផលថ្នាំជក់តាមគ្រប់រូបភាពជាអាទិ៍ ការដាក់តាំងបង្ហាញរូបសញ្ញា ផ្ទាំងគំនូរ ប័ណ្ណផ្សព្វផ្សាយ សម្ភារៈផ្សេងៗដែលមានសញ្ញាផលិតផលថ្នាំជក់ កម្មវិធីដាក់រង្វាន់ក្នុងកញ្ចប់ផលិតផលថ្នាំជក់និងកម្មវិធីផ្តល់រង្វាន់ជាសាច់ប្រាក់ដល់អ្នកជក់តាមរយៈការដាក់រង្វាន់ក្នុងកញ្ចប់ផលិតផលថ្នាំជក់ ឬសុងបារី ការប្តូរកញ្ចប់បារីទទេដើម្បីទទួលបានកញ្ចប់មានបារី ការចាប់ឆ្នោតផ្សងសំណាង និងការផ្តល់រង្វាន់ឥតគិតថ្លៃនូវទំនិញផ្សេងៗទៀតក្រៅពីផលិតផលថ្នាំជក់តាមរយៈការលើកកម្ពស់ផលិតផលថ្នាំជក់។

**ប្រការ៥.-**

បុគ្គលណាដែលរំលោភបទប្បញ្ញត្តិ នៃប្រកាសនេះត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងច្បាប់ស្តីពីការគ្រប់គ្រងពិនិត្យផលិតផលថ្នាំជក់ និងបទប្បញ្ញត្តិផ្សេងៗទៀតដែលនៅជាធរមាន។

**ប្រការ៦.-**

បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៧.-**

នាយកខុទ្ទកាល័យ អគ្គនាយករដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសុខាភិបាលដែលពាក់ព័ន្ធ ត្រូវអនុវត្តន៍តាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ២០១៥

ម៉ម_ប៊ុនហេង

**<u>កន្លែងទទួល</u>**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ដូច ប្រការ៧
- សាលារាជធានី ខេត្ត
- ឯកសារ-កាលប្បវត្តិ

# ការអនុវត្តការដាក់តាំងបង្ហាញផលិតផលថ្នាំជក់ នៅកន្លែងលក់ ឬតូបលក់ ឬហាងលក់ ផលិតផលថ្នាំជក់

ការកំណត់ផ្ទៃដាក់តាំងនិងផ្ទៃផ្សេងទៀតនៃសម្ភារសម្រាប់តាំងលក់កញ្ចប់បារីត្រូវមានពណ៌ត្នោតហើយ លាត និងមានផ្ទៃក្រឡា ២,០០០ សម$^2$ ។

កន្លែងលក់ ឬតូបលក់ ឬហាងលក់ផលិតផលថ្នាំជក់ ត្រូវបានអនុញ្ញាតឱ្យដាក់តាំងលក់ផលិតផលថ្នាំជក់ក្នុងមួយម៉ាកតែមួយកញ្ចប់ប៉ុណ្ណោះ

ក្នុងកន្លែងលក់ ឬតូបលក់ ឬហាងលក់ផលិតផលថ្នាំជក់ មិនត្រូវបានអនុញ្ញាតឱ្យធ្វើការផ្សាយពាណិជ្ជកម្ម និងការផ្សព្វផ្សាយលក់ផលិតផលថ្នាំជក់តាមគ្រប់រូបភាព។



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## វិធានការហាមការដាក់ឬការបង្ហាញផ្សាយផលិតផលថ្នាំជក់ នៅកន្លែងធ្វើការឬកន្លែងសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងការពារសុខុមាលភាពរបស់ប្រជាជន ការពារនិងទប់ស្កាត់ការឯកផ្សែងផលិតផលថ្នាំជក់ដែលបង្កឱ្យមានហានិភ័យសុខភាពដល់អ្នកនៅជុំវិញនិងបរិស្ថាន និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីវិធានការក្នុងការហាមជក់ ការបង្ហុយផ្សែងផលិតផលថ្នាំជក់ និងទីកន្លែងហាមជក់។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការជក់និងការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **ផលិតផលថ្នាំជក់** សំដៅដល់ផលិតផលគ្រប់ប្រភេទ ផ្សំឡើងពីសន្លឹកថ្នាំជក់ សរសៃថ្នាំជក់ ឬសារធាតុនៃថ្នាំជក់ ដែលផលិតដោយឧស្សាហកម្មថ្នាំជក់ឬដោយមធ្យោបាយផ្សេងៗទៀត ដែលប្រើប្រាស់សម្រាប់ជក់ដោយផ្ទាល់ឬដោយទម្រង់ផ្សេងៗទៀត រួមមាន ជញ្ជក់ ទំពា ចុក ឬហិត។
- **ការជក់** សំដៅដល់ការប្រើប្រាស់ផលិតផលថ្នាំជក់ដែលកំពុងឆេះឬកំពុងបញ្ចេញចំហាយ ទោះបីជាផ្សែងឬចំហាយនោះត្រូវបានបឺតស្រូបចូលឬបញ្ចេញមកក្រៅក្តី។
- **កន្លែងធ្វើការ** សំដៅដល់កន្លែងដែលជនណាម្នាក់បម្រើការងារជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្នក្នុងអគារ ទោះជាការងារនោះទទួលបានប្រាក់កម្រៃឬមិនយកកម្រៃ ដោយស្ម័គ្រចិត្ត ឬកាតព្វកិច្ចក្តី ក្នុងនោះរួមបញ្ចូលទាំងការិយាល័យផ្ទាល់ខ្លួន កន្លែងរួម និងកន្លែងផ្សេងទៀត ដែលជាទូទៅកន្លែងនោះត្រូវបានប្រើប្រាស់ឬចេញចូលក្នុងអំឡុងពេលបំពេញការងារ។ ក្នុងអគារ នៅទីនេះ សំដៅដល់ក្នុងទីចំហាក្នុងបន្ទប់ដែលមានដំបូលឬព័ទ្ធដោយជញ្ជាំងមួយឬច្រើនដោយមិនគិតពីប្រភេទសម្ភារៈដែលប្រើប្រាស់សម្រាប់ធ្វើជាដំបូលឬជញ្ជាំង និងដោយមិនគិតថាហេដ្ឋារចនាសម្ព័ន្ធនេះប្រើជាប្រចាំឬបណ្តោះអាសន្នឡើយ។
- **កន្លែងសាធារណៈ** សំដៅដល់កន្លែង អគារសាធារណៈបិទបាំង មធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលសាធារណជនអាចចេញចូលឬប្រើប្រាស់។
- **មធ្យោបាយដឹកជញ្ជូនសាធារណៈ** សំដៅដល់យានយន្តគ្រប់ប្រភេទ ជាអាទិ៍ រថយន្ត រថភ្លើង ជលយាន អាកាសយាន ដែលដឹកសាធារណជនទូទៅក្នុងគោលបំណងពាណិជ្ជកម្ម។

- **កន្លែងអគារសាធារណៈបិទបាំង** សំដៅដល់កន្លែងសាធារណៈដែលមានដំបូល ជញ្ជាំង ឬរបាំង មួយឬច្រើន មានឬគ្មានទ្វារ ដោយមិនគិតពីប្រភេទសម្ភារៈដែលប្រើប្រាស់សម្រាប់ធ្វើជាដំបូល ជញ្ជាំង ឬរបាំង និងដោយមិនគិតថាកន្លែងនោះត្រូវបានសង់ឬដំឡើងសម្រាប់ជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្នឡើយ។
- **គ្រឹះស្ថានសិក្សា** សំដៅដល់មជ្ឈមណ្ឌលអប់រំ សិក្សា បណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត។
- **គ្រឹះស្ថានសុខាភិបាល** សំដៅដល់ប៉ុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យ គ្លីនិកសុខភាពទាំងរដ្ឋ ទាំងឯកជន ឱសថស្ថាន មន្ទីរពិសោធន៍សុខាភិបាលជាដើម។
- **គ្រឹះស្ថានសាសនា** សំដៅដល់ព្រះវិហារ ធម្មសភា សាលាបុណ្យ កុដិ បណ្ណាល័យ សាលាពុទ្ធិកសិក្សា អាស្រម មណ្ឌលវិបស្សនា វិហារ ស៊ូរ៉ាវ ជាដើម ដែលទីកន្លែងទាំងនោះប្រើប្រាស់ក្នុងគោលបំណងគោរពបូជាសាសនាផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការណែនាំ ផ្សព្វផ្សាយ អនុវត្ត និងត្រួតពិនិត្យលើការអនុវត្តការហាមការជក់និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការនិងកន្លែងសាធារណៈ។ ក្នុងករណីចាំបាច់ ត្រូវសហការជាមួយក្រសួងនិងស្ថាប័ន ព្រមទាំងអង្គការជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ។

**មាត្រា៦ .-**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តនិងចាត់វិធានការពិន័យអន្តរការណ៍ដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៣
## វិធានការហាមឃាត់ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅកន្លែងធ្វើការឬកន្លែងសាធារណៈ

**មាត្រា៧ .-**

ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមមធ្យោបាយដឹកជញ្ជូនសាធារណៈ ត្រូវហាមឃាត់។

ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ក្នុងអគារឬក្នុងចម្ងាយ៥ម៉ែត្រពីច្រកចេញចូលនៃកន្លែងធ្វើការ កន្លែងអគារសាធារណៈបិទបាំង ត្រូវហាមឃាត់។

ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ក្នុងបរិវេណគ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសិក្សា ទារកដ្ឋាន សួនកុមារ សួនច្បារសាធារណៈ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ត្រូវហាមឃាត់។

**មាត្រា៨ .-**

គោលការណ៍ណែនាំនិងការចាត់វិធានការចាំបាច់ផ្សេងៗទាក់ទងទៅនឹងទីកន្លែងហាមឃាត់ និងកន្លែងហាមឃាត់ផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៩ .-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈ ត្រូវបិទផ្សាយឬដាក់បម្រាមអំពីការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមផ្លូវចូលនិងកន្លែងសមស្របផ្សេងទៀតដែលឱ្យសាធារណជនអាចមើលឃើញច្បាស់។ បម្រាមនេះត្រូវដាក់បញ្ជាក់អំពីប្រាក់ពិន័យនិងលេខទូរសព្ទសមត្ថកិច្ចសម្រាប់ទាក់ទង ដែលត្រូវដាក់នៅតាមកន្លែងជាក់ស្តែង។

ស្លាកបម្រាមនៃការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា១០ .-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈត្រូវបង្គាប់មិនឱ្យជក់ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ចំពោះជនណាដែលមិនអនុវត្តតាមស្លាកបម្រាមហាមជក់និងត្រូវសហការជាមួយសមត្ថកិច្ច ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា។

**មាត្រា១១ .-**

នៅកន្លែងធ្វើការ កន្លែងសាធារណៈ និងកន្លែងផ្សេងៗទៀត ដែលត្រូវបានហាមឃាត់មិនឱ្យជក់និងបង្ហុយផ្សែងផលិតផលថ្នាំជក់ មិនត្រូវដាក់តាំងឬបង្ហាញប្រដាប់គោះបារីឬរូបភាពប្រដាប់គោះបារី ទោះនៅក្នុងទម្រង់ ទំហំ និងប្រភេទណាក៏ដោយ។

**មាត្រា១២ .-**

ជនណាដែលមិនអនុវត្តតាមបម្រាមស្តីពីការហាមជក់ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ ជនណាមួយផ្សេងទៀត ត្រូវរាយការណ៍ជូនសមត្ថកិច្ច ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៣ .-**

នៅអាកាសយានដ្ឋាន អាចមានបន្ទប់សម្រាប់ជក់ឬបង្ហុយផ្សែងផលិតផលថ្នាំជក់។

## ជំពូកទី៥
## ពិន័យអន្តរការណ៍

**មាត្រា១៤ .-**

ជនណាមិនគោរពតាមបទប្បញ្ញត្តិមាត្រា៧នៃអនុក្រឹត្យនេះត្រូវពិន័យអន្តរការណ៍ជាប្រាក់២០ ០០០ (ពីរម៉ឺន)រៀល។

**មាត្រា១៥ .-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈដែលមិនអនុវត្តតាមបទប្បញ្ញត្តិ មាត្រា៩ មាត្រា១០ និងមាត្រា១១នៃអនុក្រឹត្យនេះត្រូវពិន័យអន្តរការណ៍ជាប្រាក់៥០ ០០០(ប្រាំម៉ឺន)រៀល។ ក្នុងករណីមិនរាងចាលត្រូវពិន័យទ្វេដង។

**មាត្រា១៦ .-**

បែបបទនៃការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃប្រាក់ពិន័យ និងការគ្រប់គ្រងប្រាក់ចំណូលបានមកពីការពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៧ .-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈ មានរយៈពេល៦(ប្រាំមួយ)ខែ ដើម្បីរៀបចំដាក់ស្លាកបម្រាមស្តីពីការហាមជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ ..២៧៣....ប្រ./អបស

# ប្រកាស

# ស្តីពី

# ស្លាកបម្រាមនៃការហាមការជក់ឬការបន្ទុយផ្សែងផលិតផលថ្នាំជក់

****

# រដ្ឋមន្ត្រីក្រសួងសុខាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ ២០១៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ ២០១៣ ស្តីពីការកែសម្រួលបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ចុះថ្ងៃទី២៤ ខែមករាឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងសុខាភិបាល

-បានឃើញព្រះរាជក្រមលេខនស/រកម/០៥១៥/០០៤ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ ២០១៥ ដែលប្រកាសឱ្យប្រើប្រាស់ច្បាប់ស្តីពី ការត្រួតពិនិត្យផលិតផលថ្នាំជក់

- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល

- បានឃើញអនុក្រឹត្យលេខ ៩៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែមិនា ឆ្នាំ២០១៦ ស្តីពី វិធានការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬ កន្លែងសាធារណៈ

- យោងតាមការចាំបាច់របស់ក្រសួងសុខាភិបាល

# សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងបង្ហាញកន្លែងហាមជក់ ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ដើម្បីការពារសុខុមាលភាពរបស់ប្រជាជនពីផលប៉ះពាល់នៃផលិតផលថ្នាំជក់។

**ប្រការ២.-**

ប្រកាសនេះមានគោលដៅកំណត់គំរូ និងនីតិវិធីនៃការដាក់ស្លាកបម្រាមនៃការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមទីកន្លែងធ្វើការ ឬទីកន្លែងសាធារណៈដែលហាមជក់។

**ប្រការ៣.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការដាក់ស្លាកបម្រាមនៃការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅទីកន្លែងហាមជក់ក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ៤.-**

ស្លាកបម្រាមអំពីការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ត្រូវតែជាសារសរសេរជាភាសាខ្មែរ និងភាសាអង់គ្លេស និងត្រូវអមដោយសញ្ញាបម្រាម។

ស្លាកបម្រាមត្រូវសរសេរថា "ហាមជក់បារី" "NO SMOKING" អមជាមួយនឹងសញ្ញាបម្រាមដែលមានរូបភាពបារីមួយដើមនៅក្នុងរង្វង់ក្រហម និងមានបន្ទាត់ក្រហមមួយគូសចំអង្កត់ផ្ចិតបញ្ឆិតពីខាងលើនៃផ្នែកខាងឆ្វេងមកខាងក្រោមផ្នែកខាងស្តាំដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ។

ស្លាកបម្រាមអំពីការហាមការជក់ ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ត្រូវមានទំហំអប្បបរិមា៖ សម្រាប់បរិវេណ ទំហំ ៣៤១០០ សង់ទីម៉ែត្រការ៉េ (បណ្តោយ ២២០ សង់ទីម៉ែត្រ និងទទឹង១៥៥សង់ទីម៉ែត្រ) សម្រាប់កន្លែងធ្វើការ កន្លែងអគារសាធារណៈបិទបាំងទំហំ ៦០០សង់ទីម៉ែត្រការ៉េ (បណ្តោយ៣០សង់ទីម៉ែត្រនិងទទឹង២០សង់ទីម៉ែត្រ) និងសម្រាប់មធ្យោបាយដឹកជញ្ជូនសាធារណៈ៖ ទំហំ ២០០សង់ទីម៉ែត្រការ៉េ (បណ្តោយ ២៤សង់ទីម៉ែត្រ និងទទឹង១២សង់ទីម៉ែត្រ) ។

**ប្រការ៥.-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈត្រូវបិទផ្សាយ ឬដាក់ស្លាកបម្រាមដូចមានចែងក្នុងឧបសម្ព័ន្ធនៃប្រកាសនេះនៅកន្លែងដែលសាធារណជនអាចមើលឃើញច្បាស់ជាអាទិ៍ កន្លែងចេញចូល កន្លែងទទួលភ្ញៀវ បន្ទប់ទឹក។

**ប្រការ៦.-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈអាចបោះពុម្ព ឬផលិតចែកចាយស្លាកបម្រាមនៃការហាមការជក់ ឬការបង្អូយផ្សែងផលិតផលថ្នាំជក់ទៅតាមគំរូដូចមានក្នុងឧបសម្ព័ន្ធ។

**ប្រការ៧.-**

បុគ្គលណាដែលរំលោភបទប្បញ្ញត្តិនៃប្រកាសនេះត្រូវទទួលពិន័យតាមច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់ អនុក្រឹត្យស្តីពី វិធានការហាមការជក់ឬការបង្អូយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការឬកន្លែងសាធារណៈ។

**ប្រការ៨.-**

បទប្បញ្ញត្តិណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកបច្ចេកទេសសុខាភិបាល អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានអង្គភាព ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ក្រោមឱវាទក្រសួងសុខាភិបាលដែលពាក់ព័ន្ធត្រូវអនុវត្តតាមប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី[illegible]ខែ[illegible]ឆ្នាំ២០១៦[illegible]

ម៉ម ប៊ុនហេង

**កន្លែងទទួល**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង និងស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យក្រសួងសុខាភិបាល
- សាលារាជធានី-ខេត្ត
- គណៈកម្មការអន្តរក្រសួងដើម្បីការអប់រំនិងកាត់បន្ថយការប្រើប្រាស់ថ្នាំជក់
- ដូច ប្រការ៩
- ឯកសារ-កាលប្បវត្តិ

# ហាមជក់បារី

# NO SMOKING



យោងអនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្តីពី
វិធានការហាមជក់ ឬបង្ហុយផ្សែងផលិតផល
ថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ

**ជនណាជក់បារីនៅកន្លែងហាមឃាត់ត្រូវពិន័យ 20 000 រៀល**

PENALTY APPLIED

# ហាមជក់បារី

# NO SMOKING



យោងអនុក្រឹត្យលេខ ៤៣ អនក្រ.បក ស្តីពី
វិធានការហាមជក់ ឬបង្ហុយផ្សែងផលិតផល
ថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ

**ជនណាជក់បារីនៅកន្លែងហាមឃាត់ត្រូវពិន័យ 20 000 រៀល**

**PENALTY APPLIED**

---

រៀបចំដោយ

មជ្ឈមណ្ឌលជាតិលើកកំពស់សុខភាព

The Union

International Union Against Tuberculosis and Lung Disease

*Health solutions for the poor*